# ព្រះរាជក្រម

នស/រកម/០២០៧/០០៤

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា

-បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជា ចូលរួមក្នុងអនុសញ្ញាអន្តរជាតិប្រឆាំងនឹងការប្រើប្រាស់សារធាតុជួយំញ្ញក្នុងវិស័យកីឡា ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៦ នាសម័យប្រជុំរដ្ឋសភា លើកទី៥ នីតិកាលទី៣ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០០៦ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី២ នីតិកាលទី២ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ ៖

/ 2

# ច្បាប់
# ស្តីពី
# ការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលរួមក្នុង អនុសញ្ញាអន្តរជាតិប្រឆាំងនឹងការប្រើប្រាស់សារធាតុជំរុញក្នុងវិស័យកីឡា

**មាត្រា ១.-**

អនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលរួមក្នុងអនុសញ្ញាអន្តរជាតិប្រឆាំងនឹងការប្រើប្រាស់សារធាតុជំរុញក្នុងវិស័យកីឡា ដែលធ្វើនៅទីក្រុងប៉ារីស នាថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០០៥ ដោយមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយ ។

**មាត្រា ២.-**

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបន្តរាល់នីតិវិធីដើម្បីអនុវត្តអនុសញ្ញាអន្តរជាតិនេះ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០០៧

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

នស/រកម.០១០៧.០២៩

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ
នាយករដ្ឋមន្ត្រី
ហត្ថលេខា
ហ៊ុន សែន

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី
ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា
ហត្ថលេខា
គឹម សេង

លេខ ៥៤៦ ចល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ៥ ខែ មករា ឆ្នាំ ២០០៧
អគ្គលេខាធិការរងរាជរដ្ឋាភិបាល
ស៊ុន ច័ន្ទថុល

3/3

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# អនុសញ្ញាអន្តរជាតិ

# ប្រឆាំងនឹងការប្រើប្រាស់សារធាតុជួយភ្នាក់ក្នុងវិស័យកីឡា

# សេចក្តីប្រកាសរបស់ទីក្រុងកូប៉ិនហាក
# ស្តីពីការហាមឃាត់នឹងការប្រើប្រាស់សារធាតុជំរុញកីឡា

**អ្នកចូលរួម :**

ដោយយល់ថាវិស័យកីឡាគួរដើរតួនាទីយ៉ាងសំខាន់ក្នុងកិច្ចការពារសុខភាព ការអប់រំសីលធម៌ និង ការអប់រំកាយ និងក្នុងការលើកកំពស់ការយល់ដឹងជាអន្តរជាតិ ។

ដោយប្រុងប្រយ័ត្នថាការប្រើប្រាស់សារធាតុដូប៉ាធ្វើអោយអន្តរាយដល់តំលៃរបស់វិស័យកីឡា ។

ដោយមានកង្វល់ពីការប្រើប្រាស់ភ្នាក់ងារ និងវិធីសាស្ត្រនៃការប្រើសារធាតុដូប៉ា ដោយកីឡាករ តាមរយៈកីឡា និងផលវិបាកដែលបណ្តាលមកពីការប្រើប្រាស់សារធាតុ និងវិធីសាស្ត្រទាំងនេះ ដែលប៉ះពាល់ដល់អនាគតនៃវិស័យកីឡា ។

ដោយចងចាំទុកក្នុងចិត្តនូវច្បាប់ គោលនយោបាយ និងសេចក្តីប្រកាស ប្រឆាំងនឹងការប្រើប្រាស់ សារធាតុដូប៉ា ដែលអនុម័តដោយស្ថាប័នកីឡាជាតិ និងស្ថាប័នកីឡាអន្តរជាតិ ។

ដោយដឹងថាអាជ្ញាធរសាធារណៈ និងស្ថាប័នកីឡា មានការទទួលខុសត្រូវបំពេញអោយគ្នាទៅវិញ ទៅមក ដើម្បីប្រយុទ្ធប្រឆាំងនឹងការប្រើប្រាស់សារធាតុដូប៉ាក្នុងវិស័យកីឡា ជាពិសេសដើម្បី ធានាបាននូវការប្រព្រឹត្តសមស្របក្នុងព្រឹត្តិការណ៍កីឡា ដោយផ្អែកលើមូលដ្ឋាននៃគោលការណ៍ ការចូលរួមប្រកួតស្មើភាព និងដើម្បីការពារដល់សុខភាពកីឡាករ ដែលចូលរួមក្នុងព្រឹត្តិការណ៍ កីឡាទាំងនោះ ។

ដោយទទួលស្គាល់លើការរីកចំរើន ដែលធ្វើឡើងដោយរដ្ឋាភិបាលក្នុងការប្រឆាំងទៅនឹងការប្រើ ប្រាស់សារធាតុដូប៉ារហូតមកទល់នឹងពេលបច្ចុប្បន្ននេះ ជាពិសេសទាក់ទងទៅនឹងការទទួលស្គាល់ អភិបាលកិច្ច និងការផ្តល់មូលនិធិដល់ទីភ្នាក់ងារពិភពលោកប្រឆាំងនឹងការប្រើប្រាស់សារធាតុ ដូប៉ា ការបង្កើត និងការអនុវត្តរបស់ក្រុមប្រឹក្សានៃអនុសញ្ញាអឺរ៉ុបប្រឆាំងនឹងការប្រើប្រាស់សារធាតុដូប៉ា (ETS 135) និងពិធីសារបន្ថែមរបស់ក្រុមប្រឹក្សានេះ កិច្ចសហប្រតិបត្តិការ អន្តរដ្ឋាភិបាលស្តីពី ការប្រឆាំងនឹងការប្រើប្រាស់សារធាតុដូប៉ា ដោយរាប់បញ្ចូលទាំងការចូលរួម ចំណែករបស់ក្រុម ផ្តល់ប្រឹក្សាអន្តររដ្ឋាភិបាលអន្តរជាតិស្តីពីវេទិកាប្រឆាំងនឹងការប្រើប្រាស់ សារធាតុដូប៉ាក្នុងវិស័យ កីឡា (IICGADS) និងការបង្កើតកម្មវិធីជាតិប្រឆាំងនឹងការប្រើប្រាស់ សារធាតុដូប៉ា។

ដោយទទួលស្គាល់ថាក្នុងសេចក្តីថ្លែងការណ៍ចុងក្រោយ (Final Communiqué) នៃកិច្ចប្រជុំតុមូល UNESCO របស់រដ្ឋមន្ត្រី និងមន្ត្រីជាន់ខ្ពស់ទទួលខុសត្រូវលើការអប់រំកាយ និងកីឡា ដែលធ្វើឡើងនៅទីក្រុងប៉ារីសនាថ្ងៃទី ៩ ដល់ថ្ងៃទី ១០ ខែមករា ឆ្នាំ ២០០៣ ដែលគាំទ្រដល់ការជំរុញអោយមានការរៀបចំអនុសញ្ញាអន្តរជាតិប្រឆាំងនឹងការប្រើប្រាស់សារធាតុដូប៉ាអោយបានឆាប់ដោយផ្អែកលើអនុសញ្ញាប្រឆាំងនឹងការប្រើប្រាស់សារធាតុដូប៉ារបស់ក្រុមប្រឹក្សាអឺរ៉ុប ប្រសិនបើ អាចធ្វើទៅបាន មុនកីឡាអូឡាំពិករដូវក្តៅឆ្នាំ ២០០៤ និងសំរាប់ការអនុម័ត ប្រសិនបើអាច ធ្វើទៅបាន មុនកីឡាអូឡាំពិករដូវរងាឆ្នាំ ២០០៦ ។

ដោយបានប្តេជ្ញាចិត្តអនុវត្តសកម្មភាពសហប្រតិបត្តិការបន្ថែមទៀត និង កាន់តែខ្លាំងជាងមុនក្នុងគោលបំណងកាត់បន្ថយ និងចុងក្រោយ បំបាត់ជាស្ថាពរនូវការប្រើសារធាតុដូប៉ាក្នុងវិស័យ កីឡា ។

បានឈានដល់ការយល់ដូចខាងក្រោមនេះ :

## ១. ទិសាលភាព

ក្នុងការអនុវត្តតាមកថាខ័ណ្ឌទាំងអស់នៃសេចក្តីប្រកាសនេះ អ្នកចូលរួមត្រូវធ្វើសកម្មភាពក្នុងដែនកំនត់បទបញ្ញត្តិរដ្ឋធម្មនុញ្ញរបស់ប្រទេសរៀង១ខ្លួន និងបទបញ្ញត្តិច្បាប់ផ្សេង១ទៀត និងទទួលស្គាល់ភាពខុសគ្នាក្នុងប្រព័ន្ធរដ្ឋធម្មនុញ្ញ និងច្បាប់រវាងរដ្ឋាភិបាលនានា ដោយរួមបញ្ចូលគ្នាជាមួយនឹងវិធីសាស្ត្រចម្រុះ ដើម្បីប្រយុទ្ធប្រឆាំងនឹងការប្រើប្រាស់សារធាតុដូប៉ាក្នុងវិស័យកីឡា ។

## ២. គោលបំណង

គោលបំណងនៃសេចក្តីថ្លែងការណ៍នេះ គឺដើម្បីផ្សព្វផ្សាយការយល់ដឹងពីនយោបាយ និងសីលធម៌ក្នុងចំណោមអ្នកចូលរួមដើម្បី :

២.១ ទទួលស្គាល់តួនាទី និងគាំទ្រដល់ទីភ្នាក់ងារពិភពលោកប្រឆាំងនឹងការប្រើប្រាស់សារធាតុដូប៉ា (WADA)

២.២ គាំទ្រច្បាប់ពិភពលោកប្រឆាំងនឹងការប្រើប្រាស់សារធាតុដូប៉ា ( " ច្បាប់ " ) ដែលអនុម័តដោយគណៈកម្មាធិការមូលនិធិ WADA នៅឯសន្និសីទពិភពលោកស្តីពីការប្រើសារធាតុដូប៉ាក្នុងកីឡា (ទីក្រុងកូប៉ិនហាក ថ្ងៃទី ៣ ដល់ថ្ងៃទី ៥ ខែមិនា ឆ្នាំ ២០០៣)

២.៣ ទ្រទ្រង់ដល់កិច្ចសហប្រតិបត្តិការអន្តររដ្ឋាភិបាលអន្តរជាតិ ក្នុងការបង្កើនភាពចុះសម្រុងគ្នាក្នុងគោលនយោបាយ និងការប្រតិបត្តិប្រឆាំងនឹងការប្រើប្រាស់សារធាតុដូប៉ាក្នុងកីឡា និង

២.៤ គាំទ្រដល់ដំណើរការទាន់ពេលវេលា ដែលនាំឆ្ពោះទៅរកអនុសញ្ញា ឬកាតព្វកិច្ចផ្សេងទៀតលើចំនុច ៣-៨ ដូចខាងក្រោម ដែលនឹងត្រូវអនុវត្តតាមរយៈលិខិតុបករណ៍សមស្របទៅនឹងបរិបទរដ្ឋធម្មនុញ្ញនិងរដ្ឋបាលរបស់រដ្ឋាភិបាលនីមួយៗ ត្រឹម ឬមុនថ្ងៃទីមួយនៃកីឡាអូឡាំពិករដូវរងាទីក្រុងទូរិន ។ ដំណើរការនេះគប្បីប្រើប្រាស់ជំនាញឯកទេសរបស់តំណាងរដ្ឋាភិបាលមកពីគ្រប់តំបន់ ទាំងអស់នៃពិភពលោក និងអង្គការអន្តរជាតិ ។

៣. **ការគាំទ្រចំពោះ WADA**

*អ្នកចូលរួមនីមួយៗ :*

៣.១ ទទួលស្គាល់តួនាទី និងគាំទ្រ WADA

៣.២ ស្ថិតក្រោមការកែសំរួលតាមរយៈសហប្រតិបត្តិការអន្តររដ្ឋាភិបាលដែលសមស្រប ប្រកាសគោលបំណងរបស់ខ្លួនដើម្បីបន្តទម្លាប់ប្រតិបត្តិ ដែលអាជ្ញាធរសាធារណៈបានអនុវត្តតាមក្នុងអភិបាលកិច្ច និងការផ្តល់ហិរញ្ញប្បទានដល់ WADA និងក្នុងក្របខ័ណ្ឌនេះ :

៣.២.១ គាំទ្រការបែងចែកសមាសភាពរបស់គណៈប្រតិភូអាជ្ញាធរសាធារណៈនៅក្នុងគណៈកម្មាធិការមូលនិធិ WADA ស្របតាមតំបន់អូឡាំពិក :

អ្នកតំណាង ៤ នាក់ មកពីទ្វីបអាមេរិក

អ្នកតំណាង ៣ នាក់ មកពីទ្វីបអាហ្វ្រិក

អ្នកតំណាង ៥ នាក់ មកពីអឺរ៉ុប

អ្នកតំណាង ៤ នាក់ មកពីទ្វីបអាស៊ី

អ្នកតំណាង ២ នាក់ មកពីទ្វីបអូសេអានី

៣.២.២ គាំទ្រការផ្តល់មូលនិធិដល់ WADA ដោយអាជ្ញាធរសាធារណៈ និងចលនាអូឡាំពិកដូចខាងក្រោម :

៣.២.២.១ អាជ្ញាធរសាធារណៈរួមចំណែកផ្តល់ ៥០% នៃគំរោងថវិកាស្នូលប្រចាំឆ្នាំរបស់ WADA ដែលបានអនុម័តរួច ។

៣.២.២.២ ការទូទាត់របស់អាជ្ញាធរសាធារណៈទៅអោយ WADA ស្របតាមតំបន់អូឡាំពិក :

| | |
|---|---|
| ទ្វីបអាហ្វ្រិក : | ០.៥០% |
| ទ្វីបអាមេរិក : | ២៩% |
| ទ្វីបអាស៊ី : | ២០.៤៦% |
| ទ្វីបអឺរ៉ុប : | ៤៧.៥% |
| ទ្វីបអូសេអានី : | ២.៥៤% |

**៤. គាំទ្រដល់ច្បាប់ពិភពលោកប្រឆាំងនឹងការប្រើប្រាស់សារធាតុដូប៉ា**

អ្នកចូលរួមនីមួយ ១ :

៤.១ ទទួលស្គាល់តួនាទីរបស់ច្បាប់ថាជាមូលដ្ឋានគ្រឹះមួយក្នុងប្រការប្រយុទ្ធប្រឆាំងទូទាំងពិភពលោកប្រឆាំងនឹងការប្រើប្រាស់សារធាតុដូប៉ាក្នុងកីឡា ។

៤.២ នៅទីណាដែលសមស្រប ព្យាយាមកែសំរួលអោយបានល្អប្រសើរជាងមុននូវគោលនយោបាយ និងទម្លាប់ប្រតិបត្តិប្រឆាំងនឹងការប្រើប្រាស់សារធាតុដូប៉ាក្នុងកីឡា ដើម្បីអោយមានភាពស្របគ្នាជាមួយនឹងបទបញ្ញត្តិនៃច្បាប់នេះនៅទីណាដែលសមស្រប ។

៤.៣ លើកទឹកចិត្តស្ថាប័នជាតិ និងអន្តរជាតិ ដែលជាប់ពាក់ព័ន្ធក្នុងការប្រឆាំងនឹងការប្រើប្រាស់សារធាតុដូប៉ាក្នុងកីឡា អោយអនុម័តច្បាប់ និងអោយមានដំណើរការស្របទៅតាមច្បាប់ នៅទីណាដែលសមស្រប ។

៤.៤ ចាត់វិធានការសមស្របចំពោះការបដិសេធមិនទទួលយកជំនួយគាំទ្រផ្នែកហិរញ្ញវត្ថុខ្លះ ឬទាំងអស់របស់រដ្ឋាភិបាល ដែលទាក់ទងទៅនឹងការចូលរួមក្នុងកីឡា ដែលបានមកអង្គការកីឡា កីឡាករ និងបុគ្គលិកគាំទ្រកីឡាករ ដែលមិនអនុវត្តតាមច្បាប់ ឬវិធានប្រឆាំងនឹងការប្រើប្រាស់សារធាតុដូប៉ាកំពុងមានជាធរមាន ដែលត្រូវបានអនុម័តស្របទៅតាមច្បាប់ និង

៤.៥ គាំទ្រដល់តួនាទីរបស់ WADA ក្នុងការសំរបសំរួល ធ្វើឱ្យស៊ីសង្វាក់គ្នា និងធ្វើឱ្យកិច្ចខិតខំប្រឹងប្រែងប្រឆាំងនឹងការប្រើប្រាស់សារធាតុដូប៉ាមានលក្ខណៈស្តង់ដារស្របទៅតាមច្បាប់ ។

**៥. វិធានការដាក់កំរិតលើការមាន ការប្រើប្រាស់សារធាតុនិងវិធីសាស្ត្រហាមឃាត់ក្នុងកីឡា**

៥.១ អ្នកចូលរួមនីមួយៗមានបំណងធានាអោយបានថាបទបញ្ជា វិធានការរដ្ឋបាល និងវិធានការរបស់ស្ថាប័ននីតិប្រតិបត្តិ គឺមានរួចជាស្រេចនៅនឹងកន្លែង ដើម្បី :

៥.១.១ ត្រួតពិនិត្យការមាន ( មានដូចជាការនាំចូល ការនាំចេញ ការចែកចាយ ការរត់ពន្ធ និងការផលិត ) សារធាតុ និងវិធីសាស្ត្រហាមឃាត់ និង

៥.១.២ ជំរុញអោយមានការប្រាស្រ័យទាក់ទងព័ត៌មាន ដើម្បីកាត់បន្ថយការមានសាធាតុ និងវិធីសាស្ត្រហាមឃាត់ រវាងទីភ្នាក់ងារនានាក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ។

ក្នុងការធ្វើដូច្នេះ វិធានការដែលបានអនុវត្ត មិនគួររារាំងដល់ការមានសារធាតុ និងវិធីសាស្ត្រហាមឃាត់ក្នុងកីឡាសំរាប់បំរើដល់គោលបំណងស្របច្បាប់ឡើយ ។

៥.២ អ្នកចូលរួមម្នាក់ៗត្រូវបានលើកទឹកចិត្តអោយមានការចាត់វិធានការផ្សេងៗដែលទាក់ទងទៅនឹងការប្រើអាហារបំប៉នបន្ថែមក្នុងគោលបំណងអោយកីឡាករទាំងអស់អាចទទួលបានព័ត៌មានស្តីពីជំរើសចំណីអាហារបំប៉នផ្សេងៗ ដើម្បីចៀស វាងការប្រើប្រាស់សារធាតុដូប៉ាដែលបានហាមឃាត់ ។

**៦. វិធានការជាតិប្រឆាំងនឹងការប្រើប្រាស់សារធាតុដូប៉ា**

អ្នកចូលរួមម្នាក់ៗ គប្បីផ្តល់ជំនួយហិរញ្ញវត្ថុទៅតាមមធ្យោបាយរៀងៗខ្លួន ដើម្បីជួយគាំទ្រដល់កម្មវិធីជាតិប្រឆាំងនឹងការប្រើប្រាស់សារធាតុដូប៉ា ដែលរួមមាន វិធានការត្រួតពិនិត្យលើការប្រើប្រាស់សារធាតុដូប៉ា សកម្មភាពអប់រំ ការសិក្សាស្រាវជ្រាវ និងសកម្មភាពផ្សព្វផ្សាយព័ត៌មាន ។

**៧. កិច្ចសហប្រតិបត្តិការអន្តរជាតិនៅក្នុងការត្រួតពិនិត្យលើការប្រើប្រាស់សារធាតុដូប៉ា**

ដោយទទួលស្គាល់ថា ការប្រយុទ្ធប្រឆាំងនឹងការប្រើប្រាស់សារធាតុដូប៉ានៅក្នុងវិស័យកីឡា គឺជាមធ្យោបាយដ៏មានប្រសិទ្ធភាពតែមួយគត់ ដែលក្នុងនោះ គេអាចធ្វើតេស្តលើកីឡាករដោយមិនចាំបាច់ផ្តល់ការជូនដំណឹងជាមុន និង ការទទួលគំរូរបស់រាងកាយតាមរយៈការប្រមូលសំណាក ដែលគេអាចដឹកជញ្ជូនទាន់ពេលវេលាទៅកាន់មន្ទីរពិសោធន៍ដើម្បីធ្វើវិភាគ ដូច្នេះអ្នកចូលរួមម្នាក់ៗ ត្រូវ :

៧.១. សហការជាមួយអង្គការ WADA និងអង្គការប្រឆាំងនឹងការប្រើប្រាស់សារធាតុដូប៉ាដទៃទៀត ដែលប្រតិបត្តិការក្រោមការឧបត្ថម្ភរបស់អង្គការ WADA និងត្រូវគោរពតាមច្បាប់ បទបញ្ញត្តិរបស់ម្ចាស់សាមីប្រទេស និងត្រូវចាត់វិធានការត្រួតពិនិត្យលើការប្រើប្រាស់សារធាតុដូប៉ាចំពោះកីឡាកររបស់ខ្លួន មិនថានៅក្នុងទឹកដីរបស់ខ្លួន ឬ នៅកន្លែងផ្សេងនោះទេ ។

៧.២. នៅពេលដែលសមស្រប ត្រូវសហការនៅក្នុងការបញ្ជូន ឬ ដឹកជញ្ជូនឆ្លងកាត់ព្រំដែននូវគំរូរបស់រាង កាយដែលទទួលបាន តាមរយៈការប្រមូលសំណាក ។

៧.៣. នៅពេលដែលសមស្របត្រូវទទួលស្គាល់ទៅវិញទៅមកចំពោះនីតិវិធីត្រួតពិនិត្យលើការប្រើប្រាស់សារធាតុ និងការគ្រប់គ្រងលទ្ធផលនៃការធ្វើតេស្តរបស់អង្គការប្រឆាំងនឹងការប្រើសារធាតុដូប៉ាដែលធ្វើឡើងស្របតាមច្បាប់នេះ ។

៧.៤. នៅពេលដែលសមស្រប ត្រូវសហការជាមួយអង្គការ WADA នៅក្នុងការជួយសម្របសម្រួលជាអន្តរជាតិចំពោះវិធានការត្រួតពិនិត្យលើការប្រើប្រាស់សារធាតុដូប៉ាដែលអនុវត្តធ្វើឡើងដោយអង្គការប្រឆាំងនឹងការប្រើប្រាស់សារធាតុផ្សេងៗ និង

៧.៥. លើកទឹកចិត្ត និងជួយគាំទ្រដល់ការរៀបចំធ្វើតេស្តដែលធ្វើឡើងរវាងរដ្ឋាភិបាល ឬ អង្គការក្រៅរដ្ឋាភិបាលប្រឆាំងនឹងការប្រើប្រាស់សារធាតុដូប៉ាដែលបានចាត់តាំងរួច ។

**៨. ការតាមដានត្រួតពិនិត្យលើការអនុវត្តតាម**

ការត្រួតពិនិត្យលើការបន្តការគោរពតាមការសន្យា និងការប្តេជ្ញាចិត្តផ្សេងៗដែលធ្វើឡើងនៅក្នុងអនុសញ្ញានេះ ឬ ការអនុវត្តតាមកាតព្វកិច្ចផ្សេងទៀត ត្រូវធ្វើឡើងដូចបានកំនត់នៅក្នុងការពិភាក្សារវាងអង្គការ WADA និងរដ្ឋាភិបាលពាក់ព័ន្ធផ្សេងៗ ។

**៩. អន្តរកាល**

នៅក្នុងអំឡុងពេលដែលនាំទៅដល់ការបង្កើតអនុសញ្ញាមួយ ឬ កាតព្វកិច្ចដទៃទៀត អ្នកចូលរួមទាំងឡាយអាចសុំអោយអង្គការ WADA ផ្តល់កិច្ចសហការដោយឈរលើមូលដ្ឋានជាក់ស្តែង ដើម្បីជួយដល់ការអនុវត្តបទបញ្ញត្តិនៃច្បាប់នេះ តាមសមត្ថកិច្ចជំនាញរបស់របស់រដ្ឋាភិបាល ។

<u>សេចក្តីប្រកាសរបស់ទីក្រុង កូប៊ិនហាក ស្តីពីការប្រឆាំងនឹងការប្រើប្រាស់សារធាតុជួយនៅក្នុងវិស័យកីឡា</u>

*(ហត្ថលេខា)*

ចុះហត្ថលេខានៅ ថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៥

តាងនាមអោយ : រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

ដោយ **បណ្ឌិត កុល ផេង**

មុខតំណែង : **ទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**